**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តក្រចេះ**

សំណុំរឿងព្រហ្មទណ្ឌលេខ:២៦៩

ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ**២០២៣**

សំណុំរឿងជំនុំជម្រះលេខ:៤៩៧

ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ**២០២៣**

**សាលក្រមលេខ:៤៨ "ឃ"**

ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

## សាលក្រមព្រហ្មទណ្ឌ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តក្រចេះ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តក្រចេះ

នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង០៨ និង៣០ នាទីព្រឹក និងប្រកាសសាលក្រម

នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ ដែលមានសមាសភាពដូចតទៅ ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាចៅក្រមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាចៅក្រមប្រឹក្សាជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តក្រចេះ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ:**២៦៩** ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] **សេន** ភេទប្រុស អាយុ៦២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតនៅ [redacted] ខេត្តក្រចេះ និងមានទីលំនៅសព្វថ្ងៃនៅភូមិ[redacted] ខេត្តក្រចេះ ឪពុកឈ្មោះ **ប៉ុន** (ស) ម្តាយឈ្មោះ **យ៉ា** (ស) ប្រពន្ធឈ្មោះ [redacted] **ណារេត** មានកូន០៥នាក់ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

២.ឈ្មោះ [redacted] **គីនីន** ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តក្រចេះ ទីលំនៅសព្វថ្ងៃនៅភូមិ[redacted] ខេត្តក្រចេះ មុខរបរកសិករ ឪពុកឈ្មោះ [redacted] **គីន** (រស់) ម្តាយឈ្មោះ [redacted] **អោវ៉ា** (រស់) ប្រពន្ធឈ្មោះ [redacted] **ជិអ៊ិ** មានកូន០២នាក់ ទោសពីមុនគ្មាន។ (ក្រៅឃុំ)



Scanned with CamScanner

ត្រូវជាប់ចោទពីបទ៖ **កាប់គាស់ រុករានដីព្រៃ ឆ្ការដុត និងឈូសឆាយដីព្រៃដើម្បី យកដីធ្វើជាកម្មសិទ្ធ** ប្រព្រឹត្តនៅចំណុចត្រពាំងគ្រៀលនិយាមកាX៦៦២៦០៤-Y១៤៣៣១២១ ស្ថិតនៅភូមិសាស្ត្រ ឃុំស្រែជិះ ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៦ កថាខណ្ឌ១ ចំណុច៤ និងមាត្រា៦២ កថាខណ្ឌ១ ចំណុច១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

-អ្នកបកប្រែឈ្មោះ [redacted] **ឡូ** ភេទប្រុស អាយុ២៧ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិត្នោត ឃុំស្រែជិះ ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-**បានឃើញ** ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ:៤១៣៣ ព.ស/២៣ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តក្រចេះ។

**អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ ÷**

កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង១០ និង១៥ នាទី រសៀល មានបទល្មើសធនធានធម្មជាតិ ករណី កាប់គាស់ រុករាន ឆ្ការ ដុត និងឈូសឆាយដីព្រៃយកធ្វើជាកម្មសិទ្ធិមួយកន្លែង អស់ទំហំផ្ទៃ ២,១១ ហិកតា ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] **សេន** និងឈ្មោះ [redacted] **ភីទីន** នៅចំណុចត្រពាំងគ្រៀល និយាមកាលេខ:X៦៦២៦០៤-Y១៤៣៣១២១ ស្ថិតនៅភូមិសាស្ត្រ ឃុំស្រែជិះ ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] **សេន** បានឆ្លើយថា: ខ្លួនមិនបានទៅកាប់រានដីព្រៃនៅចំណុចត្រពាំងគ្រៀលនោះទេ។ តែខ្លួនបានឱ្យកូនខ្លួនទៅដាំបង្គោលព្រំដីនៅចំណុចត្រពាំងគ្រួស ស្ថិតនៅភូមិស្រែជិះ ឃុំស្រែជិះ ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ មានទំហំជាង២ហិកតា។ ដីដែលខ្លួនបានកាន់កាប់នៅចំណុចត្រពាំងគ្រួសនោះ គឺមិនមានការដឹងឮពីអាជ្ញាធរជាលិខិតលាយលក្ខណ៍អក្សរនោះទេ។ ដីនោះខ្លួនបានកាន់កាប់ និងដាំដុះតែទំហំ ០,៥ ហិកតាតែប៉ុណ្ណោះមុនដំបូងឡើយ។ តែក្រោយពេលកូនខ្លួនរៀបការជាមួយឈ្មោះ [redacted] **ភីទីន** មកក៏ខ្លួនបានឱ្យកូនប្រសារទៅកាន់កាប់បន្តពីខ្លួន និងធ្វើរបងព័ទ្ធជុំវិញ ស្រាប់តែមានមន្ត្រីបរិស្ថានគាត់ចុះទៅហាមឃាត់មិនឱ្យធ្វើរបង និងកាន់កាប់ដីខាងលើទៀតនោះទេ ហើយខ្លួនក៏បានឱ្យកូនទៅរុះរើសរបងនោះចេញវិញ និងបានទៅប្រាប់មេភូមិខ្លួនមិនកាន់កាប់ដីខាងលើនោះទេ។ ដីនៅតំបន់ខ្លួនកាន់កាប់នោះមិនមានបំរាមហាមឃាត់ការកាប់រានដីព្រៃនោះទេ។ ដីខាងលើនោះគឺខ្លួនបានកាន់កាប់បន្តពីឪពុកខ្លួនតាំងពីឆ្នាំ១៩៨៥ រហូតមក ដោយកាន់កាប់ដីនោះមុនដំបូងឡើយមានទំហំតែ ០,៥ ហិកតា តែប៉ុណ្ណោះ និងបានពង្រីកបន្ថែមបានទំហំ២ហិកតា ដោយកាប់ដោយកាំបិត និងពូថៅ និងជួលត្រាក់ទ័រឈូសឆាយខ្លះ។ ដីតំបន់នោះមិនទាន់ផ្ទះប្រជាពលរដ្ឋរស់នោះទេ គឺមានតែចម្ការតែប៉ុណ្ណោះ ដោយចម្ការទាំងនោះ



Scanned with CamScanner

មានដាំដំឡូង និងចន្ទី។ នៅពេលកាប់រានទោះមិនមានអាជ្ញាធរចុះទៅហាមឃាត់នោះទេ ហើយចម្ការប្រជាពលរដ្ឋនៅជុំវិញនោះក៏មិនមានអាជ្ញាធរចុះទៅហាមឃាត់ដែរ ដោយអ្នកខ្លះមានទំហំ១ហិកតា និងខ្លះទៀតមានទំហំ២ហិកតា ជាដើម។ ខ្លួនមានដីកាន់កាប់ចំនួនពីរកន្លែង មួយកន្លែងនៅជិតផ្ទះ ស្ថិតនៅភូមិស្រែជិះ ឃុំស្រែជិះ ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ និងមួយកន្លែងទៀតគឺដីនៅកន្លែងមានរឿង។ ចំពោះដីដែលមានរឿងនោះគឺជាចម្ការវិលជុំ។ ដីចម្ការវិលជុំនេះមិនមានអ្នកណាទៅប៉ះពាល់របស់អ្នកណានោះទេ ហើយខ្លួនក៏មិនដែលដឹងថាដីនោះខុសច្បាប់ទេ។ ខ្លួនស្គាល់អាជ្ញាធរត្រឹមភូមិឃុំ និងប៉ុស្តិ៍ ហើយស្គាល់មន្ត្រីបរិស្ថាននៅពេលពួកគាត់ចុះទៅហាមឃាត់ខ្លួន។ ខ្លួនជា**ជនជាតិភាគតិចក្រោល** ខ្លួនពេលនេះមិនចង់បានដីខាងលើទៅកាន់កាប់បន្តទៀតទេ គឺសូមប្រគល់ជូនរដ្ឋវិញ។

-ជនជាប់ចោទឈ្មោះ [redacted] **ភីទីន** បានឆ្លើយថា ខ្លួនមិនមានដីនៅចំណុចត្រពាំងគ្រៀលនោះទេ តែខ្លួនមានដីនៅចំណុចត្រពាំងគ្រូស មានទំហំ២ហិកតា។ ពីដើមមកខ្លួនមិនដឹងថាដីនេះមានរឿងនោះទេ ទើបតែដឹងនៅពេលថ្មីៗនេះទេ។ ដីខាងលើពីដើមឡើយជាដីរបស់ឪពុកក្មេកខ្លួន ហើយខ្លួនទើបតែកាន់កាប់បានមួយឆ្នាំនេះទេ ហើយពេលដែលខ្លួនទៅកាន់កាប់នោះមិនមានបិទស្លាកហាមឃាត់នោះទេ។ បានជាខ្លួនប្រគល់ដីខាងលើជូនរដ្ឋវិញ ព្រោះមន្ត្រីបរិស្ថានគាត់បានចុះទៅហាមឃាត់រូបខ្លួន ថាបើនៅតែកាន់កាប់ទៀតគាត់នឹងកសាងសំណុំរឿងបញ្ជូនមកតុលាការ ហើយខ្លួនខ្លាចតុលាការចោទប្រកាន់ក៏បានប្រគល់ដីខាងលើជូនរដ្ឋវិញ។ ខ្លួនសូមបញ្ជាក់ថាដីដែលខ្លួនបានទៅកាន់កាប់មុនដំបូងឡើយមានទំហំ ០,៥ ហិកតា ហើយបានពង្រីកបន្ថែមរហូតបានទំហំ២ហិកតា នៅក្នុងព្រំដីរបស់ខ្លួន។ ដីដែលបានពង្រីកនោះគឺបានយកត្រាក់ទ័រទៅឈូសឆាយ។ ដីនៅតំបន់នោះគ្មានការលក់ដូរនោះទេ ហើយនៅតំបន់នោះមានការដាំដុះស្រូវ ដំឡូង ល្ពៅ និងចន្ទី។ ដីដែលខ្លួនបានអាស្រ័យផលនៅក្បែរផ្ទះហូបមិនគ្រប់គ្រាន់ ទើបខ្លួនទៅឈូសឆាយដីបន្ថែមដើម្បីបង្កបង្កើនផល។ ខ្លួនមិនដែលស្គាល់មន្ត្រីបរិស្ថានទេ ហើយក៏មិនដែលដឹងថាកាន់កាប់ដីចម្ការវិលជុំខុសច្បាប់នោះដែរ។ ចម្ការដែលខ្លួនកាន់កាប់នោះ គឺយកពូថៅ កាំបិត និងរណាយន្ត ទៅកាប់ដើមឈើដើម្បីធ្វើរបង និងបានជួលត្រាក់ទ័រទៅឈូសឆាយដើម្បីពង្រីកដីបន្ថែម ចំពោះរូបភាពដែលមន្ត្រីបរិស្ថានយកមកបង្ហាញនេះខ្លួនមិនស្គាល់ថានៅតំបន់ណានោះទេ។

-មន្ត្រីឧទ្យានុរក្សឈ្មោះ [redacted] **ផល្លា** បានឆ្លើយថា កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ខ្លួន និងក្រុមការងារបានចុះទៅកន្លែងកើតហេតុបានប្រទះឃើញស្នាមកាប់រានដីព្រៃ និងភ្លួរវាស់ បន្ទាប់មកក៏បានជួបឈ្មោះ [redacted] **ភីទីន** ហើយបានសួរឈ្មោះនេះថាកាប់ដើមឈើធ្វើអ្វី ពេលនោះឈ្មោះ [redacted] **ភីទីន** បានឆ្លើយថាកាប់យកទៅធ្វើបង្គោលរបងព័ទ្ធដី។ នៅទីតាំងតំបន់ដែលបានកាប់រាននោះគឺខ្លួនបានចុះទៅបិទស្លាកហាមឃាត់ និងបានណែនាំពលរដ្ឋមិនឱ្យកាប់រានដីព្រៃផងដែរ។ ចំពោះទីតាំងដែលបានកសាងសំណុំរឿងបញ្ជូនមកតុលាការនេះ គឺបានបិទស្លាកនៅក្បែរនោះដែរ ដោយបិទនៅតាមផ្លូវដែលអាចពលរដ្ឋមើលឃើញ។ មុនពេលខ្លួនកសាងសំណុំរឿងបញ្ជូនមកតុលាការខ្លួនបានសួរមេភូមិថាដីខាងលើនេះជារបស់អ្នក



Scanned with CamScanner

ណា ហើយមេភូមិបានឆ្លើយថាជាដីរបស់ឈ្មោះ [redacted] **សេន**។ ចំពោះការដាក់ស្លាកនេះគឺខ្លួនបានដាក់ស្លាកជាអក្សរ គឺអាចមើលឃើញ និងយល់បាន។ នៅតំបន់នោះមានទំហំ៣ពាន់ហិកតាអនុក្រឹត្យកំណត់ត្រឹមត្រូវ មន្ត្រីបរិស្ថានបានចុះទៅផ្សព្វផ្សាយតាមមេភូមិ មេឃុំ ដើម្បីឱ្យពួកគាត់ចុះទៅអប់រំប្រជាពលរដ្ឋបន្ថែម ដើម្បីកុំឱ្យពួកគាត់ចុះទៅកាប់រានដីព្រៃទៀត ដែលជាអំពើខុសច្បាប់។ ពេលអនុក្រឹត្យកំណត់អំពីទំហំដីនោះបានចេញមក គឺមន្ត្រីនៃមន្ទីរបរិស្ថានខេត្តក្រចេះ បានរៀបចំយុត្តិសាស្ត្រ និងចុះទៅផ្សព្វផ្សាយដល់ពលរដ្ឋ។ ចំពោះដីដែលស្ថិតនៅទីតាំងដែលបានកាប់រាននោះគឺស្ថិតនៅក្នុងអនុក្រឹត្យចាស់ ហើយបានបង្កើតអនុក្រឹត្យថ្មី។ ដើមឈើដែលបានកាប់រាននោះមានដើមឈើធំៗ មានថ្លុង ត្បែង ជាដើម។ ចំពោះទីតាំងត្រពាំងគ្រៀល ឬត្រពាំងគ្រួសនោះ គឺខ្លួនបានសួរទៅមេភូមិ ហើយមេភូមិគាត់បានប្រាប់ថាដីខាងលើនេះស្ថិតនៅចំណុចត្រពាំងគ្រៀល ទើបខ្លួនកសាងសំណុំរឿងមកដាក់ថាចំណុចត្រពាំងគ្រៀលទៅ។

-សាក្សីឈ្មោះ [redacted] **ណូវ៉ា** ជាមន្ត្រីឧទ្យានុរក្សបានឆ្លើយថា: នៅពេលខ្លួនចុះល្បាតព្រៃនោះ គឺបានឃើញស្នាមកាប់រើរានដីព្រៃមួយកន្លែង ដែលជនជាប់ចោទបានឈូសឆាយរួចហើយ។ ដីនៅតំបន់ដែលបានកាប់រាននោះ គឺមិនមានផ្ទះរបស់ប្រជាពលរដ្ឋនោះទេ គឺមានតែព្រៃ និងចម្ការតិចតួចប៉ុណ្ណោះ។ ដីនៅតំបន់នោះ គឺខ្លួនបានបិទស្លាកនៅដើមឈើ ដោយដើមឈើមានដើមធ្លិកធំៗ ហើយជនជាប់ចោទបានយករណាយន្តទៅកាប់ដើមឈើដើម្បីយកធ្វើរបង ហើយដីដែលបានកាប់រាននៅតំបន់នោះគឺបានធ្វើការកាប់រានតាមគ្នា។

-សាក្សីឈ្មោះ [redacted] **តូច** ជាមេឃុំស្រែជិះ បានឆ្លើយថា: ដីនៅកន្លែងកើតហេតុមិនមែននៅចំណុចត្រពាំងគ្រៀលនោះទេ គឺនៅចំណុចត្រពាំងគ្រួស ដោយចំណុចត្រពាំងគ្រៀល និងត្រពាំងគ្រួសមានចម្ងាយពីគ្នាប្រហែលជា៦គីឡូម៉ែត្រ។ ចំពោះដីរបស់ឈ្មោះ [redacted] **សេន** និងឈ្មោះ [redacted] **ភីនីន** គឺមិនស្ថិតនៅក្នុងអនុក្រឹត្យក្រោមការគ្រប់គ្រងរបស់បរិស្ថាននោះទេ។ ចំពោះដីខាងលើនោះឈ្មោះ [redacted] **សេន** បានកាន់កាប់តាំងពីឆ្នាំ១៩៨៥ មកម្ល៉េះ។ ពលរដ្ឋរស់នៅឃុំស្រែជិះទាំងអស់ទាក់ទងនឹងការកាន់កាប់ដីគឺពុំទាន់មានប្លង់ ឬលិខិតកាន់កាប់ដីធ្លីនោះទេ ដោយពួកគាត់កាន់កាប់តាមទម្លាប់ពួកគាត់តាំងពីបុរាណមក។ ខ្លួនបានចូលរួមផ្សព្វផ្សាយពីការធ្វើប្លង់ដីនេះដែរ ហើយភូមិបាលស្រុកក៏បានចុះទៅផ្សព្វផ្សាយផងដែរ។ ខ្លួនទើបបានធ្វើជាមេឃុំស្រែជិះនៅឆ្នាំ២០២២ ហើយពីមុនខ្លួនធ្វើជាជំនួយការឃុំ។ ដីរបស់ឈ្មោ[redacted] **សេន** គឺមិនស្ថិតនៅក្រោមអនុក្រឹត្យស្តីពីគ្រប់គ្រងដីរដ្ឋនោះទេ។

-សាក្សីឈ្មោះ [redacted] **ផល្លា** បានឆ្លើយថា ដីរបស់ឈ្មោះ [redacted] **សេន** គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់បរិស្ថាន ដែលស្ថិតនៅក្រោមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

-សាក្សីឈ្មោះ [redacted] **តូច** បានឆ្លើយ ខ្លួនបានឃើញឈ្មោះ [redacted] **សេន** ទៅកាន់រានដោយផ្ទាល់ ហើយក្រោយពេលកើតហេតុឈ្មោះ [redacted] **សេន** បានប្រាប់ខ្លួនថាគាត់សូមប្រគល់ដីជូនរដ្ឋវិញតាមរយៈមេភូមិ ហើយមេភូមិបានមកប្រាប់ខ្លួនបន្ត។



Scanned with CamScanner

-សាក្សីឈ្មោះ [redacted] ធី បានឆ្លើយថា: ដីខាងលើនេះខ្លួនបានឃើញឈ្មោះ [redacted] សេន បានកាន់កាប់ជាយូរមកហើយ។ កាលពីកន្លងទៅដីខាងលើនេះខ្លួនបានឃើញមានស្នាមកាប់រំរានដែរ តែខ្លួនមិនដឹងថាអ្នកណាជាអ្នកកាប់រំរានទេ។ ខ្លួនជាអ្នកស្រុកដែលកើតនៅនឹងឃុំស្រែជិះនឹងតែម្តង ចំណែកឈ្មោះ [redacted] សេន ក៏ជាអ្នកកើតនៅនឹងឃុំស្រែជិះនេះដែរ។ ខ្លួនបានឃើញនៅលើដីដែលមានរឿងនេះ មានខ្ទមមួយនៅលើដី និងមានចម្ការពលរដ្ឋជាច្រើននៅជាប់គ្នា មានដាំដំឡូង ស្រូវ និងចន្ទី។ ខ្លួនមិនបានឃើញឈ្មោះ [redacted] សេន កាប់រានដីព្រៃនោះទេ តែខ្លួនបានឃើញពលរដ្ឋជាច្រើនធ្វើចម្ការនៅតំបន់នោះ។ ខ្លួនសូមបញ្ជាក់បន្ថែមថា ចំណុចត្រពាំងគ្រៀល និងត្រពាំងគ្រួសគឺនៅឆ្ងាយពីគ្នា។

-សាក្សីឈ្មោះ [redacted] ហេន បានឆ្លើយថា: ខ្លួនមិនដឹងថាដីដែលបញ្ជូនមកជំនុំជម្រះនេះនៅចំណុចណានោះទេ ហើយខ្លួនមានចម្ការនៅតំបន់នោះដែរ តែមិនដែលមានអ្នកណាទៅប្រាប់ខ្លួនថាកាន់កាប់ដីតំបន់នោះខុសច្បាប់នោះទេ ហើយក៏មិនមានអាជ្ញាធរណាទៅប្រាប់នោះដែរ។

-សាក្សីឈ្មោះ [redacted] សាវុធ បានឆ្លើយថា ខ្លួនមិនស្គាល់រូបភាពដែលចៅក្រមលើកមកបង្ហាញនោះទេ។ ដីរបស់ខ្លួនគឺនៅជាប់នឹងដីរបស់ឈ្មោះ [redacted] សេន ដែរ។

-**តំណាងអយ្យការសន្និដ្ឋានប្តឹងសុំ** ក្រោយពីបានស្តាប់ការដេញដោលលើជនជាប់ចោទនាពេលសវនាការ និងសាក្សីដែលមានចូលរួមពីអាជ្ញាធរភូមិឃុំ ជំទប់ និងមន្ត្រីបរិស្ថានរួចមក យើងរកឃើញថាពិតជាមានអង្គហេតុកាប់រានដីព្រៃ ឈូសឆាយដីព្រៃ ដើម្បីយកធ្វើជាកម្មសិទ្ធិនៅចំណុចនិយាមកាលេខ: X៦៦២៦០៤-Y១៥៣៣១២១ អស់ទំហំ ២,១១ ហិកតា ពិតមែន។ នៅពេលសវនាការជនជាប់ចោទឈ្មោះ [redacted] សេន បានឆ្លើយបញ្ជាក់ថាដីនេះគឺគាត់បានកាន់កាប់បន្តពីឪពុករបស់គាត់តាំងពីឆ្នាំ១៩៨៥ មកម្ល៉េះ ដែលជាដីចម្ការវិលជុំតាំងពីដូនតារបស់គាត់ ហើយគាត់បានផ្ទេរទៅឱ្យកូនប្រសារឈ្មោះ [redacted] ភីទីន កាន់កាប់បន្ត។ ក្នុងរបាយការណ៍របស់មន្ត្រីបរិស្ថាននៅថ្ងៃកើតហេតុដំបូងគឺមិនបានជួបម្ចាស់ទីតាំងនោះទេ ក្រោយមកដោយការខិតខំចុះទៅបង្ក្រាបក៏បានជួបជនជាប់ចោទឈ្មោះ [redacted] ភីទីន ហើយក៏បានសាវតាទាំងអស់នេះបញ្ជូនមកតុលាការ។ ពេលសវនាការនេះជនជាប់ចោទទាំងពីរនាក់នេះដែរ ពុំមានចរិតណាមួយកោងកាចមិនសហការជាមួយតុលាការនោះទេ គឺទទួលស្គាល់ថាខ្លួនពិតជាបានកាន់កាប់ដីខាងលើនេះពិតប្រាកដមែន ហើយគោលដៅនៃការកាន់កាប់របស់ជនជាប់ចោទគឺដើម្បីតម្រូវការគ្រួសារ ហើយការកាប់ព្រៃនេះទៀតសោតគឺតាមទំនៀមទំលាប់ជនជាតិដើមភាគតិចជាចម្ការវិលជុំ ហើយកាន់កាប់ក៏មិនស្ថិតស្ថេរដូចអ្នកស្រុកក្រោមនោះដែរ គឺមានដីគឺការពារ និងធ្វើប្លង់កាន់កាប់ហើយ តែពួកគាត់កាន់តាមទំនៀមទំលាប់ជនជាតិដើមភាគតិច។ ដូច្នេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ដដែលទៅលើជនជាប់ចោទឈ្មោះ [redacted] សេន និងឈ្មោះ [redacted] ភីទីន ពីបទ **កាប់គាស់ រុករានដីព្រៃ ឆ្ការដុត និងឈូសឆាយដីព្រៃ ដើម្បី យកដីធ្វើជាកម្មសិទ្ធ** ប្រព្រឹត្តនៅចំណុចត្រពាំងគ្រៀលនិយាមកាX៦៦២៦០៤-Y១៥៣៣១២១ ស្ថិតនៅភូមិសាស្ត្រ ឃុំស្រែជិះ ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ



Scanned with CamScanner

២០២៣ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៦ កថាខណ្ឌ១ ចំណុច៤ និងមាត្រា៦២ កថាខណ្ឌ១ ចំណុច១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។ ហើយសូមឱ្យក្រុមប្រឹក្សាពិចារណាពីចរិតលក្ខណៈរបស់ជនជាប់ចោទទាំងពីរនាក់ ដោយជនជាប់ចោទមិនមានចរិតគេចវេសពីការទទួលខុសត្រូវនោះឡើយ ហើយមួយវិញទៀតសូមឱ្យតុលាការពិចារណាអំពីការយល់ដឹងរបស់ជនជាប់ចោទ គឺជា "**ជនជាតិភាគតិចក្រោល**" ដែលការយល់ដឹងរបស់ពួកគាត់មានកម្រិត ហើយជនជាប់ចោទក៏បានធ្វើលិខិតមួយដោយមានខ្លឹមសារសូមប្រគល់ដីខាងលើនេះជូនរដ្ឋវិញ និងសូមឱ្យតុលាការសម្រេចរឹបអូសផ្ទៃដីដែលបានកាប់រានជូនរដ្ឋវិញ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានស្នើសុំថា ផ្អែកតាមការដេញដោលនាពេលសវនាការរួចមកឃើញថា ពិតជាមានអង្គហេតុនៃការកាប់រានដីព្រៃពិតមែន។ ប៉ុន្តែពាក់ព័ន្ធទៅនឹងអង្គហេតុនេះ គឺយើងឃើញថាមានវិមតិសង្ស័យច្រើន។ ទី១ តំបន់ ដោយកូនក្តីខ្លួនបានបញ្ជាក់តំបន់ច្បាស់ហើយទីតាំងដែលកូនក្តីខ្លួនបានកាប់រាននោះគឺនៅចំណុចត្រពាំងគ្រួស ចំណែកអង្គហេតុដែលចោទប្រកាន់គឺនៅចំណុចត្រពាំងគ្រៀល ដោយមានចម្ងាយពីគ្នាប្រហែលជា៦គីឡូម៉ែត្រ ដូច្នេះសូមឱ្យក្រុមប្រឹក្សាពិចារណាទៅលើចំណុចនេះ។ ទី២ ពាក់ព័ន្ធដែលមន្ត្រីបរិស្ថានគាត់ចោទប្រកាន់កូនក្តីខ្លួនថាទៅនៅលើដីអនុក្រឹត្យសរសរស្តម្ភ ប៉ុន្តែនិយាមកាដែលចោទប្រកាន់កូនក្តីខ្លួនគឺមិនមាននៅក្នុងអនុក្រឹត្យ ដែលទើបសម្រេចនៅខែតុលា ឆ្នាំ២០២៣ នេះទេ ដូច្នេះដីរបស់កូនក្តីខ្លួនគឺមិនស្ថិតនៅក្រោមការគ្រប់គ្រងដែលមន្ត្រីបរិស្ថានបានប្តឹងនោះទេ បន្ថែមទៀតខ្លួនបង្ហាញឱ្យមន្ត្រីបរិស្ថានពិនិត្យមើលទៅលើចំណុចនិយាមកាហ្នឹង ព្រោះនិយាមកានៅក្នុងដែននេះមានច្រើនណាស់ ប៉ុន្តែនិយាមកាដែលគាត់បានធ្វើការចោទប្រកាន់មកលើកូនក្តីខ្លួន គឺមិនមានចូលទៅក្នុងចំណុចនិយាមកាហ្នឹងទេ។ មួយវិញទៀតពាក់ព័ន្ធទៅនឹងអនុក្រឹត្យមួយទៀត កូនក្តីរបស់ខ្លួន បើនិយាយពាក់ព័ន្ធទៅនឹងចេតនាទុច្ចរិតក្នុងការចូលទៅកាន់កាប់ដីខាងលើនេះ ដូចជាមិនមានទេ ព្រោះការកាន់កាប់របស់កូនក្តីខ្លួនមានយូរមកហើយ មិនមែនទើបតែចូលទៅកាន់កាប់ ក្រោយពេលបរិស្ថានចេញអនុក្រឹត្យហើយគាត់ចូលទៅកាន់កាប់នោះទេ ដោយកូនក្តីខ្លួនបានរស់នៅមុន ទើបតែបរិស្ថានទៅតាមក្រោយទេ។ ដូចតំណាងអយ្យការបានបញ្ជាក់អ៊ីចឹងគឺជនជាតិភាគតិចគាត់មានសិទ្ធិពិសេសដែលច្បាប់ភូមិបាលផ្តល់សិទ្ធិឱ្យគាត់ក្នុងការរស់នៅទីហ្នឹង។ ទី៣ ការរស់នៅរបស់កូនក្តីខ្លួន មេឃុំក៏បានបញ្ជាក់ហើយថា កូនក្តីខ្លួនគឺជាជនជាតិដើមភាគតិច "**ក្រោល**" ពិតប្រាកដ ហើយការរស់នៅពួកគាត់គឺអាស្រ័យផលតាមទំនៀមទំលាប់របស់ជនជាតិដើមភាគតិច ចំណែកចេតនារបស់កូនក្តីខ្លួនគ្រាន់តែទៅអាស្រ័យផលលើដីនោះទេ គឺកូនក្តីខ្លួនមិនមានចេតនាកាប់ទំហំ២ហិកតា ហើយទៅកាប់ទំហំ២ហិកតាទៀត ហើយលក់អាទំហំ២ហិកតាមុន ទៅកាប់រា៣ ទើបចេតនាគាត់ខូច។ មួយទៀតវិញឃើញថាកូនក្តីខ្លួនឈ្មោះ [redacted] **សេន** ដែលជាឪពុកនេះ គាត់គ្រាន់តែចង្អុលបង្ហាញទេ ហើយអ្នកដែលបានប្រព្រឹត្តនោះគឺកូនប្រសារគាត់ឈ្មោះ [redacted] **ភីនីន** អ៊ីចឹងសូមឱ្យក្រុមប្រឹក្សាពិចារណាទៅលើចំណុចនេះដែរ។ បន្ថែមពីលើនេះ

ដែរទៀតគឺចំណុចនិយាមកា និងតំបន់ដែលចោទប្រកាន់ទៅលើកូនក្ដីខ្លួនគឺតំបន់ថ្មគ្រួស និងត្រពាំងត្រៀល សូមឱ្យក្រុមប្រឹក្សាពិចារណាទៅលើចំណុចនេះ។ ពិសេសជាងនេះទៅទៀតគឺសូមឱ្យក្រុមប្រឹក្សាពិចារណាទៅលើចំណុចនិយាមកាដែលចោទប្រកាន់កូនក្ដីខ្លួននឹង គឺមិនមាននៅក្នុងដែនជម្រកសត្វដែលមន្ត្រីបរិស្ថានចោទប្រកាន់ទេ។ ជាចុងក្រោយសំណូមពរសូមឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាទៅលើមាត្រា៣ មាត្រា៤ និងមាត្រា៥ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាលឆ្នាំ២០០១ សូមឱ្យពិចារណាទៅលើសិទ្ធិរបស់ជនជាតិដើមភាគតិច ដែលគាត់មានសិទ្ធិពិសេសទៅលើដីធ្លីនៅក្នុងមូលដ្ឋានដែលគាត់រស់នៅ។ ដូច្នេះសូមឱ្យក្រុមប្រឹក្សាទម្លាក់បទប្រកាន់ទៅលើកូនក្ដីខ្លួន។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថាៈ ខ្លួនសូមបន្ថែមនូវសេចក្ដីសន្និដ្ឋានជាមួយសហភាតារបស់ខ្លួន ត្រង់ចំណុចដែលទាក់ទងទៅនឹងអនុក្រឹត្យស្ដីពីការកែប្រែតំបន់ប្រើប្រាស់ច្រើនយ៉ាងសរសេរស្អុចុងកាល អ៊ីចឹងបើយើងឃើញទាក់ទងទៅនឹងការសួរដេញដោលខាងមន្ត្រីបរិស្ថានបានលើកឡើងថាករណីនេះកើតឡើងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ យ៉ាងមិញយើងមើលនៅក្នុងអនុក្រឹត្យនេះវាថ្មី ដោយបង្កើតឡើងនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ក្រោយនេះទេ។ អ៊ីចឹងកន្លែងនេះហើយដែលខ្លួនសូមឱ្យក្រុមប្រឹក្សាធ្វើការសម្គាល់នូវចំណុចនេះផងដែរ។

-សំណូមពរ និងជាសម្ដីចុងក្រោយជនជាប់ចោទ សូមឱ្យតុលាការទម្លាក់បទចោទប្រកាន់។

**ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ**

**ក្រោយពីបានស្ដាប់ចម្លើយសាក្សី**

**ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ**

**ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

**ក្រោយពីបានពិនិត្យលើភស្តុតាង**

**ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ៖**

**សំអាងហេតុ**

**១.យល់ឃើញថា៖** តាមចម្លើយរបស់ជនជាប់ចោទចោទឈ្មោះ [redacted] **សេន** បានបង្ហាញឱ្យឃើញថាខ្លួនបានកាន់ដីនៅចំណុចត្រពាំងគ្រួស តាំងពីឆ្នាំ១៩៨៥ មកម្ល៉េះ ដោយកាន់កាប់ដំបូងមានទំហំ ០,៥ ហិកតា ដោយបានធ្វើស្រែ លុះក្រោយពេលកូនខ្លួនរៀបការជាមួយឈ្មោះ [redacted] **ភីទីន** ហើយខ្លួនក៏បានឱ្យកូនប្រសារឈ្មោះ [redacted] **ភីទីន** ទៅកាន់កាប់បន្ត និងបានជួលត្រាកទ័រឈូសឆាយ និងកាប់ឆ្ការបន្ថែមបានទំហំ២ហិកតា និងបានធ្វើរបងព័ទ្ធជុំវិញដី ស៊ីសង្វាក់គ្នាជាមួយចម្លើយជនជាប់ចោទឈ្មោះ [redacted] **ភីទីន** បង្ហាញឱ្យឃើញថាខ្លួនពិតជាបានទៅកាប់ឆ្ការព្រៃ និងបានជួលត្រាក់ទ័រទៅឈូសឆាយពង្រីកដីស្រែដែលឪពុករបស់ខ្លួនឈ្មោះ [redacted] **សេន** ឱ្យនៅចំណុចត្រពាំងគ្រួស ស្ថិតនៅភូមិស្រែជិះ ឃុំស្រែជិះ ស្រុកអូរគ្រៀងញៀនសែនជ័យ ខេត្តក្រចេះ ពិតប្រាកដមែន។



Scanned with CamScanner

**២. យល់ឃើញថា៖** តាមចម្លើយសាក្សីឈ្មោះ [redacted] **តូច**, ឈ្មោះ [redacted] **ធិ** , ឈ្មោះ [redacted] **ហេន**, ឈ្មោះ [redacted] **សារុធ** និងសាក្សីជាមន្ត្រីបរិស្ថានឈ្មោះ [redacted] **វណ្ណ** និងឈ្មោះ [redacted] **ណូរ៉ា** បានបង្ហាញឱ្យឃើញថាជនជាប់ចោទឈ្មោះ [redacted] **សេន** និងឈ្មោះ [redacted] **ភីនីន** ពិតជាបានជួលត្រាក់ទ័រទៅឈូសឆាយដីព្រៃ និងកាន់កាប់ដីព្រៃនៅចំណុចនិយាមកាលេខ: X៦៦២៦០៤-Y១៤៣៣១២១ ស្ថិតនៅភូមិសាស្ត្រ ឃុំស្រែជិះ ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ ពិតប្រាកដមែន។

**៣.យល់ឃើញថា៖** តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការបានសន្និដ្ឋានថា ក្រោយពីបានស្តាប់ការដេញដោលលើជនជាប់ចោទនាពេលសវនាការ និងសាក្សីដែលមានចូលរួមពីអាជ្ញាធរភូមិ ឃុំ ជំទប់ និងមន្ត្រីបរិស្ថានរួចមក យើងរកឃើញថាពិតជាមានអង្គហេតុកាប់រានដីព្រៃ ឈូសឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិនៅចំណុចនិយាមកាលេខ: X៦៦២៦០៤-Y១៤៣៣១២១ អស់ទំហំ ២,១១ ហិកតា ពិតមែន។ នៅពេលសវនាការជនជាប់ចោទឈ្មោះ [redacted] **សេន** បានឆ្លើយបញ្ជាក់ថាដីនេះគឺគាត់បានកាន់កាប់បន្តពីឪពុករបស់គាត់តាំងពីឆ្នាំ១៩៨៥ មកម្ល៉េះ ដែលជាដីចម្ការវិលជុំតាំងពីដូនតារបស់គាត់ ហើយគាត់បានផ្ទេរទៅឱ្យកូនប្រសារឈ្មោះ [redacted] **ភីនីន** កាន់កាប់បន្ត។ ក្នុងរបាយការណ៍របស់មន្ត្រីបរិស្ថាននៅថ្ងៃកើតហេតុដំបូងគឺមិនបានជួបម្ចាស់ទីតាំងនោះទេ ក្រោយមកដោយការខិតខំចុះទៅបង្ក្រាបក៏បានជួបជនជាប់ចោទឈ្មោះ [redacted] **ភីនីន** ហើយក៏បានសាវតាទាំងអស់នេះបញ្ជូនមកតុលាការ។ ពេលសវនាការនេះជនជាប់ចោទទាំងពីរនាក់នេះដែរ ពុំមានចរិតណាមួយកោងកាចមិនសហការជាមួយតុលាការនោះទេ គឺទទួលស្គាល់ថាខ្លួនពិតជាបានកាន់កាប់ដីខាងលើនេះពិតប្រាកដមែន ហើយគោលដៅនៃការកាន់កាប់របស់ជនជាប់ចោទគឺដើម្បីតម្រូវការគ្រួសារ ហើយការកាប់ព្រៃនេះទៀតសោតគឺតាមទំនៀមទំលាប់ជនជាតិដើមភាគតិចជាចម្ការវិលជុំ ហើយកាន់កាប់ក៏មិនស្ថិតស្ថេរដូចអ្នកស្រុកក្រោមនោះដែរ គឺមានដីគឺការពារ និងធ្វើប្តូរកាន់កាប់ហើយ តែពួកគាត់កាន់តាមទំនៀមទំលាប់ជនជាតិដើមភាគតិច។ ដូច្នេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ដដែលទៅលើជនជាប់ចោទឈ្មោះ [redacted] **សេន** និងឈ្មោះ [redacted] **ភីនីន** ពីបទ **កាប់គាស់ រុករានដីព្រៃ ឆ្ការដុត និងឈូសឆាយដីព្រៃដើម្បី យកដីធ្វើជាកម្មសិទ្ធ** ប្រព្រឹត្តនៅចំណុចត្រពាំងគ្រៀលនិយាមកាX៦៦២៦០៤-Y១៤៣៣១២១ ស្ថិតនៅភូមិសាស្ត្រ ឃុំស្រែជិះ ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៦ កថាខណ្ឌ១ ចំណុច៤ និងមាត្រា៦២ កថាខណ្ឌ១ ចំណុច១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។ ហើយសូមឱ្យក្រុមប្រឹក្សាពិចារណាពីចរិតលក្ខណៈរបស់ជនជាប់ចោទទាំងពីរនាក់ដោយជនជាប់ចោទមិនមានចរិតគេចវេសពីការទទួលខុសត្រូវនោះឡើយ ហើយមួយវិញទៀតសូមឱ្យតុលាការពិចារណាអំពីការយល់ដឹងរបស់ជនជាប់ចោទ គឺជា "**ជនជាតិភាគតិចក្រោល**" ដែលការយល់ដឹងរបស់ពួកគាត់មានកម្រិត ហើយជនជាប់ចោទក៏បានធ្វើលិខិតមួយដោយមានខ្លឹមសារសូមប្រគល់ដីខាងលើនេះជូនរដ្ឋវិញ និងសូមឱ្យតុលាការសម្រេចរឹបអូសផ្ទៃដីដែលបានកាប់រានជូនរដ្ឋវិញ។

**៤.យល់ឃើញថា៖** តាមសេចក្តីសន្និដ្ឋានស្នើសុំរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានស្នើសុំថា ផ្អែកតាមការដេញដោលនាពេលសវនាការរួចមកឃើញថា



Scanned with CamScanner

ពិតជាមានអង្គហេតុនៃការកាប់រានដីព្រៃពិតមែន។ ប៉ុន្តែពាក់ព័ន្ធទៅនឹងអង្គហេតុនេះ គឺយើងឃើញថាមានវិមតិសង្ស័យច្រើន។ ទី១ តំបន់ ដោយកូនក្តីខ្លួនបានបញ្ជាក់តំបន់ច្បាស់ហើយទីតាំងដែលកូនក្តីខ្លួនបានកាប់រាននោះគឺនៅចំណុចត្រពាំងគ្រួស ចំណែកអង្គហេតុដែលចោទប្រកាន់គឺនៅចំណុចត្រពាំងគ្រៀល ដោយមានចម្ងាយពីគ្នាប្រហែលជា៦គីឡូម៉ែត្រ ដូច្នេះសូមឱ្យក្រុមប្រឹក្សាពិចារណាទៅលើចំណុចនេះ។ ទី២ ពាក់ព័ន្ធដែលមន្ត្រីបរិស្ថានគាត់ចោទប្រកាន់កូនក្តីខ្លួនថាទៅនៅលើដីអនុក្រឹត្យសរសរស្តម្ភ ប៉ុន្តែនិយាមកាដែលចោទប្រកាន់កូនក្តីខ្លួនគឺមិនមាននៅក្នុងអនុក្រឹត្យ ដែលទើបសម្រេចនៅខែតុលា ឆ្នាំ២០២៣ នេះទេ ដូច្នេះដីរបស់កូនក្តីខ្លួនគឺមិនស្ថិតនៅក្រោមការគ្រប់គ្រងដែលមន្ត្រីបរិស្ថានបានប្តឹងនោះទេ បន្តិចទៀតខ្លួនបង្ហាញឱ្យមន្ត្រីបរិស្ថានពិនិត្យមើលទៅលើចំណុចនិយាមកាហ្នឹង ព្រោះនិយាមកានៅក្នុងដែននេះមានច្រើនណាស់ ប៉ុន្តែនិយាមកាដែលគាត់បានធ្វើការចោទប្រកាន់មកលើកូនក្តីខ្លួន គឺមិនមានចូលទៅក្នុងចំណុចនិយាមកាហ្នឹងទេ។ មួយវិញទៀតពាក់ព័ន្ធទៅនឹងអនុក្រឹត្យមួយទៀត កូនក្តីរបស់ខ្លួន បើនិយាយពាក់ព័ន្ធទៅនឹងចេតនាទុច្ចរិតក្នុងការចូលទៅកាន់កាប់ដីខាងលើនេះ ដូចជាមិនមានទេ ព្រោះការកាន់កាប់របស់កូនក្តីខ្លួនមានយូរមកហើយ មិនមែនទើបតែចូលទៅកាន់កាប់ ក្រោយពេលបរិស្ថានចេញអនុក្រឹត្យហើយគាត់ចូលទៅកាន់កាប់នោះទេ ដោយកូនក្តីខ្លួនបានរស់នៅមុន ទើបតែបរិស្ថានទៅតាមក្រោយទេ។ ដូចតំណាងអយ្យការបានបញ្ជាក់អ៊ីចឹងគឺជនជាតិភាគតិចគាត់មានសិទ្ធិពិសេសដែលច្បាប់ភូមិបាលផ្តល់សិទ្ធិឱ្យគាត់ក្នុងការរស់នៅទីហ្នឹង។ ទី៣ ការរស់នៅរបស់កូនក្តីខ្លួន មេឃុំក៏បានបញ្ជាក់ហើយថា កូនក្តីខ្លួនគឺជាជនជាតិដើមភាគតិច "**ក្រោល**" ពិតប្រាកដ ហើយការរស់នៅពួកគាត់ គឺអាស្រ័យផលតាមទំនៀមទំលាប់របស់ជនជាតិដើមភាគតិច ចំណែកចេតនារបស់កូនក្តីខ្លួនគ្រាន់តែទៅអាស្រ័យផលលើដីនោះទេ គឺកូនក្តីខ្លួនមិនមានចេតនាកាប់ទំហំ២ហិកតា ហើយទៅកាប់ទំហំ២ហិកតាទៀត ហើយលក់អាទំហំ២ហិកតាមុន ទៅកាប់អា៣ ទើបចេតនាគាត់ខូច។ មួយទៀតវិញឃើញថាកូនក្តីខ្លួនឈ្មោះ [redacted] **សេន** ដែលជាឪពុកនេះ គាត់គ្រាន់តែចង្អុលបង្ហាញទេ ហើយអ្នកដែលបានប្រព្រឹត្តនោះគឺកូនប្រសារគាត់ឈ្មោះ [redacted] **ភីនីន** អ៊ីចឹងសូមឱ្យក្រុមប្រឹក្សាពិចារណាទៅលើចំណុចនេះដែរ។ បន្ថែមពីលើនេះដែរទៀតគឺចំណុចនិយាមកា និងតំបន់ដែលចោទប្រកាន់ទៅលើកូនក្តីខ្លួនគឺតំបន់ថ្មគ្រួស និងត្រពាំងគ្រៀលសូមឱ្យក្រុមប្រឹក្សាពិចារណាទៅលើចំណុចនេះ។ ពិសេសជាងនេះទៅទៀតគឺសូមឱ្យក្រុមប្រឹក្សាពិចារណាទៅលើចំណុចនិយាមកាដែលចោទប្រកាន់កូនក្តីខ្លួននឹង គឺមិនមាននៅក្នុងដែនជម្រកសត្វដែលមន្ត្រីបរិស្ថានចោទប្រកាន់ទេ។ ជាចុងក្រោយសំណូមពរសូមឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាទៅលើមាត្រា៣ មាត្រា៤ និងមាត្រា៥ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាលឆ្នាំ២០០១ សូមឱ្យពិចារណាទៅលើសិទ្ធិរបស់ជនជាតិដើមភាគតិចដែលគាត់មានសិទ្ធិពិសេសទៅលើដីធ្លីនៅក្នុងមូលដ្ឋានដែលគាត់រស់នៅ។ ដូច្នេះសូមឱ្យក្រុមប្រឹក្សាទម្លាក់បទប្រកាន់ទៅលើកូនក្តីខ្លួន។



Scanned with CamScanner

**៥.យល់ឃើញថា៖** តាមសេចក្តីសន្និដ្ឋានស្នើសុំរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានសន្និដ្ឋានថា: ខ្លួនសូមបន្ថែមនូវសេចក្តីសន្និដ្ឋានជាមួយសហភាតារបស់ខ្លួន ត្រង់ចំណុចដែលទាក់ទងទៅនឹងអនុក្រឹត្យស្តីពីការកែប្រែតំបន់ប្រើប្រាស់ច្រើនយ៉ាងសរសេរស្តម្ភចុងកាល អ៊ីចឹងបើយើងឃើញទាក់ទងទៅនឹងការសួរដេញដោលខាងមន្ត្រីបរិស្ថានបានលើកឡើងថាករណីនេះកើតឡើងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ យ៉ាងមិញយើងមើលនៅក្នុងអនុក្រឹត្យនេះវាថ្មី ដោយបង្កើតឡើងនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ក្រោយនេះទេ។ អ៊ីចឹងកន្លែងនេះហើយដែលខ្លួនសូមឱ្យក្រុមប្រឹក្សាធ្វើការសម្គាល់នូវចំណុចនេះផងដែរ។

**៦.យល់ឃើញថា៖** ជនជាប់ចោទជានីតិជន ដែលមានស្មារតីធម្មតាអាចយល់ដឹងនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត និងបច្ច័យដែលកើតឡើងពីអំពើនោះ។

**៧.យល់ឃើញថា៖** មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **សេន** ភេទប្រុស និងឈ្មោះ [redacted] **ភីឌីន** ភេទប្រុស ពីបទ **កាប់គាស់ រុករានដីព្រៃ ឆ្ការដុត និងឈូសឆាយដីព្រៃដើម្បី យកដីធ្វើជាកម្មសិទ្ធ** ប្រព្រឹត្តនៅចំណុចនិយាមកាX៦៦២៦០៤-Y១៤៣៣១២១ ស្ថិតនៅភូមិសាស្រ្ត ឃុំស្រែជិះ ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិ ឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៦ កថាខណ្ឌ១ ចំណុច៤ និងមាត្រា៦២ កថាខណ្ឌ១ ចំណុច១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**៨.យល់ឃើញថា៖** ជនជាប់ចោទឈ្មោះ [redacted] **សេន** និងឈ្មោះ [redacted] **ភីឌីន** បានឆ្លើយសារភាពពីកំហុសរបស់ខ្លួន ហើយក៏បានប្រគល់ដីដែលខ្លួនបានកាប់រានជូនរដ្ឋវិញដែរ ហើយតុលាការផ្តន្ទាទោសជនជាប់ចោទស្របតាមលក្ខខណ្ឌដែលអាចឱ្យតុលាការសម្រេចព្យួរទោសធម្មតាដល់ជនជាប់ចោទបាន។

**៩.យល់ឃើញថា៖** ផ្ទៃដីដែលបានកាប់រានមានទំហំ ២,១១ ហិកតា គឺជាវត្ថុដែលជាកម្មវត្ថុដែលត្រូវតុលាការសម្រេចរឹបអូសតាមបញ្ញត្តិមាត្រា៥៦ នៃច្បាប់ស្តីពីតំបន់កាពារធម្មជាតិ។

**ហេតុដូច្នេះសម្រេចសេចក្តី**

**១.ផ្តន្ទាទោសលើជនជាប់ចោទដូចខាងក្រោម៖**

១.១ ឈ្មោះ [redacted] **សេន** ភេទប្រុស អាយុ៦២ឆ្នាំ (អត្តសញ្ញាណដូចខាងលើ)

១.២ ឈ្មោះ [redacted] **ភីឌីន** ភេទប្រុស អាយុ៣៥ឆ្នាំ (អត្តសញ្ញាណដូចខាងលើ)

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន **១៥.០០០.០០០ (ដប់ប្រាំលាន) រៀល** តែអនុវត្តទោសព្យួរធម្មតាទាំងមូល ពីបទ **កាប់គាស់ រុករានដីព្រៃ ឆ្ការដុត និងឈូសឆាយដីព្រៃដើម្បី យកដីធ្វើជាកម្មសិទ្ធ** ប្រព្រឹត្តនៅចំណុចនិយាមកាលេខ: X៦៦២៦០៤-Y១៤៣៣១២១ ស្ថិតនៅភូមិសាស្រ្ត ឃុំស្រែជិះ ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៦ កថាខណ្ឌ១ ចំណុច៤ និងមាត្រា៦២ កថាខណ្ឌ១ ចំណុច១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។



Scanned with CamScanner

២.របែរអូសផ្ទៃដីទំហំ ២,១១ ហិកតា នៅចំណុចនិយាមកាលេខ:X៦៦២៦០៤-Y១៤៣៣១២១ ស្ថិតនៅភូមិសាស្ត្រ ឃុំស្រែជិះ ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី**១៧ ខែមករា ឆ្នាំ២០២៤** ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី**៣១ ខែមករា ឆ្នាំ២០២៤**។

បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|

**ហត្ថលេខា និងត្រា** [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃពុធ ០៦រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅខេត្តក្រចេះ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

បានឃើញ
ប្រធានក្រុមប្រឹក្សា

[redacted]

ក្រឡាបញ្ជីសវនាការ

[redacted]



Scanned with CamScanner